# សុន្ទរកថា
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ លើកទី ៧៣
## ទីក្រុងញូវយ៉ក, ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៨

****+****

**លោកជំនាវប្រធាន !**

ការចូលរួមរបស់ខ្ញុំនៅក្នុងមហាសន្និបាតពេលនេះ គឺស្ថិតក្នុងបរិការណ៍ដែលប្រជាជាតិកម្ពុជាកំពុងតែសប្បាយរីករាយទទួលផលពីសុខសន្តិភាព, ស្ថិរភាព, និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស, ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រសម័យទំនើបរបស់ខ្លួន ។ កម្ពុជា គឺជាករណីជោគជ័យសំខាន់មួយរបស់ប្រទេសដែលធ្លាប់ត្រូវបានញាំញីដោយសង្គ្រាម ហើយសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មីគួរជាទីមោទនៈ ។

ពីប្រទេសមួយដែលធ្លាប់តែត្រូវបានគេស្គាល់ថា ជាវាលពិឃាដ, ជាតំបន់អសន្តិសុខ ដោយសារជម្លោះប្រដាប់អាវុធ និងសំណល់គ្រាប់មីនដ៏គ្រោះថ្នាក់, និងជាប្រទេសមានសេដ្ឋកិច្ចអន់ថយ, ផុងជាប់ក្នុងភាពក្រីក្រ, និងមានអសន្តិសុខស្បៀង; កម្ពុជាបច្ចុប្បន្នទទួលបានសន្តិភាពពេញលេញ និងបានក្លាយជាគោលដៅទេសចរណ៍ដ៏មានប្រជាប្រិយនៅតំបន់អាស៊ីអាគ្នេយ៍, ជាប្រទេសនាំចេញស្បៀងអាហារ, មានស្នាដៃលេចធ្លោក្នុងការកាត់បន្ថយភាពក្រីក្រ និងការកែលំអសូចនាករសង្គមនានា, និងជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅក្នុងពិភពលោក ដែលថ្មីៗនេះ បានឆ្លងផុតដោយជោគជ័យពីឋានៈជាប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ដោយសារកំណើនសេដ្ឋកិច្ចដ៏ខ្ពស់, ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ, ក្នុងរយៈពេលជាងពីរទស្សវត្សរ៍កន្លងមក ។

ពីប្រទេសដែលល្បីក្នុងការប្រើអាវុធ ដើម្បីដណ្តើមអំណាចគ្នា និងក្នុងការផ្លាស់ប្តូររដ្ឋាភិបាល, ឥឡូវនេះ កម្ពុជាបានក្លាយជាប្រទេសដែលគ្រប់គ្រងដោយនីតិរដ្ឋ ហើយគោរពយ៉ាងមុតមាំនូវគោល-ការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ជាមួយនឹងការរៀបចំការបោះឆ្នោតដោយទៀងទាត់, សេរី, និង យុត្តិធម៌, ដើម្បីផ្តល់សិទ្ធិឱ្យប្រជាជនអាចជ្រើសរើសមេដឹកនាំប្រទេស ។

នៅក្នុងការបោះឆ្នោតសកលដើម្បីជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៦ កាលពីខែ កក្កដា កន្លងទៅថ្មីៗនេះ, អ្នកបោះឆ្នោតកម្ពុជាជិត ៧ លាននាក់, ឬស្មើនឹង ៨៣,០២% នៃចំនួនអ្នកចុះឈ្មោះបោះឆ្នោតសរុប, បានទៅបោះឆ្នោត និងបានសម្រេចយកនូវជម្រើសនយោបាយរបស់ពួកគេ ដោយសេរី និងដោយគ្មានការបង្ខិតបង្ខំ ឬ ការគំរាមកំហែង ឬ អំពើហិង្សាណាមួយឡើយ ។ គណបក្សនយោបាយ

ចំនួន ២០ បានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនេះ ដែលជាការបង្ហាញយ៉ាងច្បាស់នូវភាពជាតំណាងស្របច្បាប់នៃនយោបាយពហុនិយម និងឆ្លុះបញ្ចាំងនូវអ្វីដែលអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិរាប់ម៉ឺននាក់បានបរិយាយថា ជាដំណើរការលទ្ធិប្រជាធិបតេយ្យប្រកបដោយស្ថិរភាពនៅកម្ពុជា និងជាការបោះឆ្នោតមានលក្ខណៈសេរី, យុត្តិធម៌, និងអាចជឿទុកចិត្តបាន ។

តាមរយៈសន្លឹកឆ្នោតរបស់ពួកគេ, ប្រជាជនកម្ពុជាបានបញ្ជាក់ជាថ្មីម្តងទៀត នូវបំណងប្រាថ្នាចង់បាននូវសុខសន្តិភាព, ស្ថិរភាព, និងការអភិវឌ្ឍប្រកបដោយចីរភាពជាប់មិនដាច់ ។ ជាការពិត, ជម្រើសដោយសេរីរបស់ប្រជាជនកម្ពុជា និងលទ្ធផលប្រកបដោយធម្មានុរូបនៃការបោះឆ្នោតនេះ មិនមែនជាប្រធានបទដែលត្រូវចោទសួរ ឬ ពិភាក្សាដេញដោលនោះទេ ។ ក៏ប៉ុន្តែ, មជ្ឈដ្ឋានខាងក្រៅមួយចំនួនដែលចិញ្ចឹមជាប់នូវមហិច្ឆតាប៉ុនប៉ងជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា នៅតែធ្វើជាមើលមិនឃើញនូវគុណភាព និងសុចរិតភាពនៃដំណើរការបោះឆ្នោតរបស់យើង តាមរយៈការចេញសេចក្តីថ្លែងការណ៍នានា ប្រឆាំងនឹង ឬ វាយប្រហារលើលទ្ធផលនៃការបោះឆ្នោតនេះ ដែលទង្វើបែបនេះ គឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរចំពោះឆន្ទៈរបស់ប្រជាជនកម្ពុជា ។

**លោកជំទាវប្រធាន !**

ខ្ញុំសូមទាញអារម្មណ៍សមាជិកអង្គការសហប្រជាជាតិទាំងអស់ អំពីសារៈសំខាន់នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។ វាអាស្រ័យលើយើងគ្រប់គ្នា នៅក្នុងការផ្តល់ការគោរពដ៏ត្រឹមត្រូវចំពោះធម្មនុញ្ញដ៏មានសារៈសំខាន់នេះ ដោយត្រូវចៀសវាងការជ្រៀតជ្រែក, ការធ្វើឱ្យអន្តរាយ, ឬ ការរំខានដល់កិច្ចការអធិបតេយ្យរបស់រដ្ឋឯករាជ្យ ។ យើងមានការសោកស្តាយជាពន់ពេក ក្នុងការរំលេចនូវតថភាពដែលថាសិទ្ធិមនុស្សនាពេលបច្ចុប្បន្ននេះ បានក្លាយទៅជា **«បេសកកម្មដើម្បីបំពាក់អរិយធម៌»** សម្រាប់ប្រទេសមានអំណាចមួយចំនួន ឬ ក៏អាចនិយាយបានថា ជានិយាមប្រតិបត្តិថ្មីរបស់ពួកគេ ដែលជាលេសសម្រាប់រាល់ការលូកដៃជ្រៀតជ្រែក ក្រោមផ្លាកការពារសិទ្ធិនយោបាយ ។

ជាលទ្ធផល, ការដាក់ទណ្ឌកម្មជាឯកតោភាគីបានក្លាយទៅជាអាវុធដ៏ពេញនិយមរបស់ប្រទេសមានអំណាច នៅក្នុងការគ្រប់គ្រងនយោបាយអន្តរជាតិ ដែលស្ថិតនៅក្រោមរបៀបវារៈភូមិសាស្រ្តនយោបាយរបស់គេ ។ ទាំងនេះ គឺគ្មានអ្វីក្រៅពីការប្រើអំណាចដោយកំរោលរបស់រដ្ឋមួយ ដើម្បីបន្ទុបឆន្ទៈរបស់ខ្លួនទៅលើរដ្ឋអធិបតេយ្យដទៃនោះឡើយ ។ នៅក្នុងពិភពលោកមួយដែលសម័យកាលចក្រពត្តិនិយម និងអាណានិគមនិយម បានក្លាយទៅជាព្រឹត្តិការណ៍ប្រវត្តិសាស្រ្តទៅហើយនោះ, យើងត្រូវទទួលស្គាល់ថាមិនមែនគ្រប់ប្រទេសទាំងអស់នៅក្នុងអង្គមហាសន្និបាតនេះ ចាំបាច់ត្រូវតែដើរតាមគំរូនៃការគ្រប់គ្រងរបស់ប្រទេសដទៃណាមួយនោះទេ ។ ប្រទេសធំៗ មិនគួរដាក់បន្ទុបប្រព័ន្ធគ្រប់គ្រងរដ្ឋរបស់ពួកគេមកលើប្រទេសនានាដែលតូចជាងខ្លួននោះឡើយ ព្រោះប្រទេសតូចៗទាំងនេះ ក៏មានអធិបតេយ្យភាព និងមាន

សេចក្តីប្រាថ្នាស្របច្បាប់ក្នុងការរក្សានូវអត្តសញ្ញាណរបស់ខ្លួនដែរ ។ នៅក្នុងសម័យកាលនៃពិភពលោក ដែលមានការពឹងផ្អែកទៅវិញទៅមក, ផ្នត់គំនិតចាប់បង្ខំដ៏ចាស់គំរិលទាំងនេះ គួរតែត្រូវបានបញ្ចប់ ។ ទាំងអស់គ្នា, ទាំងប្រទេសធំ ទាំងប្រទេសតូច, ត្រូវតែរួមគ្នាគោរព និងលើកតម្កើងវិធាននៃច្បាប់អន្តរជាតិ និងធម្មនុញ្ញអង្គការសហប្រជាជាតិ ។

**លោកជំនាវប្រធាន !**

ពិភពលោកបច្ចុប្បន្ន កំពុងជួបប្រទះអស្ថិរភាពកាន់តែធ្ងន់ធ្ងរ ហើយការគំរាមកំហែងចំពោះសន្តិភាព ក៏កើតមានកាន់តែច្រើនសណ្ឋាន គឺច្រើនជាងអ្វីដែលយើងធ្លាប់បានឃើញក្នុងរយៈពេល ២៥ ឆ្នាំកន្លងទៅនេះ ។ យើងកំពុងរស់នៅក្នុងពិភពលោកមួយដែលងាយនឹងប្រែប្រួល, មិនអាចព្យាករណ៍បាន, ជាមួយនឹងការផ្លាស់ប្តូរយ៉ាងស្មុគស្មាញ និងការប្រឈមកាន់តែធំពីគ្រប់មុខព្រួញ រាប់ចាប់ពីការកើនឡើងនៃជម្លោះហិង្សាដែលអូសបន្លាយ និងវិបត្តិមនុស្សធម៌ដែលមិនធ្លាប់មានពីមុនមក ។

យើងមានការបារម្ភយ៉ាងខ្លាំង ចំពោះភាពតានតឹងដែលបង្កឡើងដោយមហាអំណាចពិភពលោកលំដាប់ទីមួយ នៅក្នុងរង្វង់ទំនាក់ទំនងការទូត និង ជម្លោះផ្ទៃក្នុងជាច្រើនកន្លែងដែលកំពុងកើតឡើងដោយសារការជ្រៀតជ្រែកពីសំណាក់មហាអំណាចនេះ ។ យើងក៏មានកង្វល់ជាខ្លាំងផងដែរ ចំពោះការសម្រេចចិត្តយ៉ាងតក់ក្រហល់របស់មហាអំណាចនេះ ក្នុងការដកខ្លួនចេញពីកិច្ចព្រមព្រៀងអន្តរជាតិនានាដ៏សំខាន់ជាសកល ដែលជាការគំរាមកំហែងដល់ស្នូលនៃភាពស្របច្បាប់នៅក្នុងសណ្តាប់ធ្នាប់គតិយុត្តិអន្តរជាតិ ។ សកម្មភាពជាឯកតោភាគីទាំងនេះ បាននិងកំពុងធ្វើឱ្យចុះខ្សោយនូវទំនាក់ទំនងរវាងបណ្តារដ្ឋ និងបង្កភាពតានតឹងនៅក្នុងសហគមន៍អន្តរជាតិ ។ ប៉ុន្តែ, អ្វីដែលបង្កសម្ពាធធ្ងន់ធ្ងរបំផុតនោះ គឺការវាយប្រហារដោយត្រង់ទៅលើ **«ពហុភាគីនិយម»** ។ ប្រាកដណាស់ថា នៅក្នុងពិភពសាកលភាវូបនីយកម្មរបស់យើង, អ្វីៗគ្រប់យ៉ាងត្រូវបានផ្សារភ្ជាប់គ្នា ។ ប្រសិនបើយើងចាប់ផ្តើមប្រកាន់គោលនយោបាយគាំពារនិយម ឯកតោភាគីនិយម និងធ្វើសង្គ្រាមពាណិជ្ជកម្ម, នោះយើងនឹងបិទទ្វារលែងឱ្យមានកាលានុវត្តភាព ពាណិជ្ជកម្ម និងការវិនិយោគ ដែលធ្លាប់បាននាំមកនូវវិបុលភាពដល់ប្រទេសយើង, ទាំងតូច, ទាំងធំ, ជាច្រើនទសវត្សរ៍មកហើយ ។ ជាលទ្ធផលចុងក្រោយ, គឺយើងទាំងអស់គ្នាប្រាកដជានឹងកាន់តែក្រ, កំណើនសេដ្ឋកិច្ចរបស់យើងនឹងធ្លាក់ចុះ, ធនធានហិរញ្ញវត្ថុរបស់យើងនឹងថមថយ, ហើយលទ្ធភាពក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏ដូចជាក្នុងការដោះស្រាយបញ្ហាប្រឈមបង្កឡើងដោយការប្រែប្រួលអាកាសធាតុ នឹងទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ។ កត្តាទាំងអស់នេះ នឹងធ្វើឱ្យប្រទេសក្រីក្រទន់ខ្សោយ ស្ថិតក្នុងស្ថានភាពក្រីក្រអូសបន្លាយកាន់តែយូរ ហើយប្រទេសទាំងនេះក៏ងាយនឹងទទួលរងផលប៉ះពាល់ពីមនោគមវិជ្ជាដ៏គ្រោះថ្នាក់នៃភេរវកម្ម, លទ្ធិជ្រុលនិយម និងជម្លោះតំបន់ ។

កម្ពុជា, ក្នុងនាមជាប្រទេសដែលមានសេដ្ឋកិច្ចតូច, ជឿលើអត្ថប្រយោជន៍នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ឈរលើវិធានគតិយុត្តិ ។ ជាការពិតណាស់, យើងបានរីកចម្រើនដោយសារសកលភាវូបនីយកម្ម ។ ហេតុនេះហើយ បានជាយើងជឿថា ពាណិជ្ជកម្មពិភពលោក មិនគួរត្រូវបានរាំងស្ទះដោយសារការកំណត់ពន្ធជាឯកតោភាគីនោះទេ; ប៉ុន្តែ គួរតែត្រូវបានលើកតម្កើង និងគាំទ្រ តាមរយៈការប្រកាន់នូវគោលនយោបាយអំណោយផលសមស្រប ព្រមទាំង ការផ្តល់ក្របខ័ណ្ឌអនុគ្រោះពិសេសដល់ប្រទេសកំពុងអភិវឌ្ឍន៍ ។ ស្ថិរភាព និងការធ្វើពិពិធកម្មលើវិស័យហិរញ្ញវត្ថុ គួរត្រូវបានលើកកម្ពស់ដើម្បីជម្រុញឱ្យមាននវានុវត្តភាព និងការអភិវឌ្ឍ ។ សរុបមក, យើងត្រូវរួមគ្នាថែរក្សា និងពង្រឹងរបប **«ពហុភាគីនិយម»** ។

ជាការពិត, សន្តិភាពដែលគ្មានការអភិវឌ្ឍ មិនអាចនៅស្ថិតស្ថេរបានឡើយ ។ ក្នុងបរិបទនេះ, **«គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព»** របស់អង្គការសហប្រជាជាតិ មានតួនាទីសំខាន់ណាស់ក្នុងការនាំផ្លូវយើងឆ្ពោះទៅរកការនាំមកនូវវិបុលភាពជូនប្រជាជន ។ កម្ពុជាយល់ថា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺជាកាលានុវត្តភាពដ៏សំខាន់សម្រាប់កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងមានបរិយាប័ន្ន ។ រាជរដ្ឋាភិបាលកម្ពុជានឹងអនុម័តក្នុងពេលដ៏ឆាប់ខាងមុខនេះ នូវ **«គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា»** ដែលត្រូវបានធ្វើជាតូបនីយកម្មពេញលេញ ហើយយើងនឹងប្រើប្រាស់គោលដៅទាំងនេះដើម្បីតម្រង់ទិសគោលនយោបាយ និងផែនការរយៈពេលមធ្យម និងរយៈពេលវែងរបស់កម្ពុជា ។

បន្ថែមលើនេះ, ការទប់ស្កាត់ជម្លោះ គឺជាបុរេល័ក្ខខ័ណ្ឌសម្រាប់សន្តិភាពចីរកាល ។ កងរក្សាសន្តិភាពអង្គការសហប្រជាជាតិ មានតួនាទីដ៏សំខាន់ពិសេសនៅជួរមុខក្នុងកិច្ចប្រឹងប្រែងនេះ ។ ហេតុដូច្នេះហើយ ទើបកម្ពុជាស្វាគមន៍យ៉ាងខ្លាំងក្លា ចំពោះទស្សនវិស័យរបស់ឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ **អាន់តូនីញ៉ូ ហ្គូតេរ៉េស** ស្តីពីការកសាង និងរក្សាសន្តិភាព ជាពិសេស លើការបន្តផ្តោតការយកចិត្តទុកដាក់ទប់ស្កាត់ជម្លោះ ។ កម្ពុជាគឺជាអ្នកគាំទ្រប្រកបដោយសង្គតិភាពចំពោះនិម្មាបនកម្មសន្តិភាព និងសន្តិសុខរបស់អង្គការសហប្រជាជាតិ ។ ជាក់ស្តែង, អស់រយៈពេល ១២ ឆ្នាំមកហើយ ដែលកម្ពុជាបានចូលរួមបញ្ជូនកងកម្លាំងមួកខៀវរាប់ពាន់នាក់ ទៅបំពេញប្រតិបត្តិការរក្សាសន្តិភាពក្រោមឆ័ត្រអង្គការសហប្រជាជាតិ ។ ក៏ប៉ុន្តែ, ការរក្សាសន្តិភាពកំពុងជួបប្រទះនឹងបញ្ហាប្រឈមដែលពុំធ្លាប់មានពីមុនមក ដោយតួអង្គមិនមែនរដ្ឋ បានបង្កសង្គ្រាមឧទ្ទាមវាយប្រហារមកលើកងកម្លាំងរក្សាសន្តិភាពរបស់យើង បណ្តាលឱ្យបាត់បង់ជីវិត និងពិការជាច្រើននាក់ ។ យើងជំពាក់គុណដ៏ធំធេង ចំពោះពលិកម្មរបស់វីរៈបុរសថែរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិទាំងអស់នេះ ។ យ៉ាងណាក្តី, មរណភាព និងពលិកម្មរបស់ពួកគេ ពុំបានកែប្រែនូវការប្តេជ្ញាចិត្តរបស់យើងក្នុងការបន្តរួមចំណែកដល់បុព្វហេតុដ៏ឧត្តុង្គឧត្តមនេះឡើយ ។

ការគំរាមកំហែងដ៏ធ្ងន់ធ្ងរ និងស្មុគស្មាញមួយទៀត ដែលជាឧបសគ្គដ៏ធំចំពោះសន្តិភាពចីរកាល គឺភេរវកម្ម ។ ពួកគេបំបែកបំបាក់សហគមន៍នានា ធ្វើឱ្យជម្លោះកាន់តែធ្ងន់ធ្ងរ និងធ្វើឱ្យតំបន់ទាំងមូលបាត់បង់ស្ថិរភាព ។ បច្ចុប្បន្ន, សមរភូមិប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មមានលក្ខណៈកាន់តែស្មុគស្មាញ និងទំនើប ដោយសារពួកភេរវករបានងាកទៅប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យាព័ត៌មាន (Cyberspace) ។ ច្បាស់ណាស់ថា សារធាតុឆ្លងដែននៃភេរវកម្ម តម្រូវឱ្យយើងកសាងកិច្ចសហប្រតិបត្តិការពហុភាគីដែលមានការសម្របសម្រួលល្អ ដែលរួមបញ្ចូលទាំង **«វិធានការប្រឆាំងតប»** និង **«វិធានការបង្ការ និងទប់ស្កាត់»** ផងដែរ ។

ការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ គឺជាធាតុផ្សំដ៏សំខាន់មួយផ្សេងទៀតសម្រាប់ជោគជ័យនៃរបៀបវារៈឆ្នាំ ២០៣០ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ និងមិនបែកខ្ញែកពីសំណាក់សហគមន៍សកល ។ គ្មានមន្ទិលទេថា មូលដ្ឋានគ្រឹះសម្រាប់សកម្មភាពដោះស្រាយបញ្ហាអាកាសធាតុ គឺកិច្ចព្រមព្រៀងទីក្រុងប៉ារីស ។ ក្នុងស្មារតីនេះ, យើងនឹងផ្តល់ការគាំទ្រពេញទំហឹងដល់ឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងការរៀបចំកិច្ចប្រជុំកំពូលស្តីពីអាកាសធាតុនៅឆ្នាំក្រោយ ដើម្បីជំរុញមហិច្ឆតាដោះស្រាយបញ្ហាអាកាសធាតុកាន់តែខ្លាំងក្លាឡើងថែមទៀត។

**លោកជំទាវប្រធាន !**

នៅចុងបញ្ចប់, ខ្ញុំសូមបញ្ជាក់ថា កម្ពុជាគាំទ្រយ៉ាងពេញទំហឹងចំពោះភាពជាអ្នកដឹកនាំជាសកលរបស់អង្គការសហប្រជាជាតិ និងប្តេជ្ញាអនុវត្តនូវការទទួលខុសត្រូវរួមរបស់យើង ក្នុងកិច្ចប្រឹងប្រែងកសាងសង្គមមួយនៃមនុស្សជាតិដែលប្រកបដោយសន្តិភាព, សមធម៌, និងមានការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ។

***ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ !***